# ពេលដើម្បីរៀបចំខ្លួន

*ដោយអែលឌើរ អ៊ីអាន អេស អាឌិន*
*នៃពួកចិតសិបនាក់*

ជំពូកទី 8 នៃសៀវភៅ *ប្រកាសដំណឹងល្អរបស់យើង* ធ្វើឲ្យយើងយកចិត្តទុកដាក់ក្នុងការប្រើពេលវេលាឲ្យឆ្លាតវៃ ។ នៅកថាកណ្ឌផ្ដើម អែលឌើរ អិម រ័សុល បាឡឺដ រំឭកយើងថា យើងត្រូវតែដាក់គោលដៅ ហើយរៀនពីរបៀបប្រើជំនាញឲ្យបានស្ទាត់ដើម្បីសម្រេចគោលដៅនានា ( សូមមើល *ប្រកាសដំណឹងល្អរបស់យើង ៖ សៀវភៅណែនាំសម្រាប់ការបម្រើរបស់អ្នកផ្សព្វផ្សាយសាសនា* [ ឆ្នាំ 2004 ] ទំព័រ 149 ) ។ ការប្រើការប៉ិនប្រសប់ដែលត្រូវការឲ្យស្ទាត់ជំនាញ ដើម្បីឈោងចាប់គោលដៅយើង រួមមានទាំងការក្លាយជាអ្នកគ្រប់គ្រងលើពេលវេលាយើងឲ្យស្ទាត់ជំនាញផងដែរ ។

ខ្ញុំមានអំណរគុណចំពោះគំរូរបស់ប្រធាន ម៉នសុន ។ រាល់អ្វីទាំងអស់ដែលលោកធ្វើក្នុងនាមជាព្យាការីនៃព្រះ លោកត្រូវធ្វើឲ្យប្រាកដថា មានពេលគ្រប់គ្រាន់ដើម្បីទៅសួរសុខទុក្ខអ្នកឈឺ ( សូមមើល លូកា 17:12 ) ដើម្បីលើកអ្នកដែលមានវិញ្ញាណទន់ខ្សោយ និងធ្វើជាអ្នកបម្រើដល់មនុស្សទាំងអស់ ដូចជាព្រះអង្គសង្គ្រោះបានធ្វើ ។

ខ្ញុំក៏មានអំណរគុណចំពោះគំរូនៃមនុស្សជាច្រើនទៀតដែលចំណាយពេលខ្លួនក្នុងការបម្រើដល់អ្នកដទៃ ។ខ្ញុំសូមថ្លែងទីបន្ទាល់ថា ពេលវេលាយើងក្នុងការបម្រើអ្នកដទៃនឹងធ្វើឲ្យព្រះសព្វព្រះទ័យ ហើយថាការធ្វើបែបនេះនឹងនាំយើងឲ្យខិតជិតទ្រង់ ។

ព្រះអង្គសង្គ្រោះយើងនឹងគោរពចំពោះបន្ទូលទ្រង់ថា « អ្នកណាដែលស្មោះត្រង់ហើយឈ្លាសវៃក្នុងវេលាកាល នោះរាប់ថាសមនឹងបានគ្រងវិមានទាំងឡាយទុកជាមរតក ដែលបានរៀបចំទុកសម្រាប់អ្នកនោះដោយព្រះវរបិតា » ( គ. និង ស. 72:4 ) ។

ពេលវេលាគឺពុំមែនសម្រាប់លក់ដូរឡើយ ទោះជាអ្នកខិតខំយ៉ាងណាក្ដី ក៏ពេលវេលាជារបស់មួយដែលមិនអាចទិញបានតាមហាងក្នុងតម្លៃណាមួយឡើយ តែបើវាត្រូវបានគេប្រើដោយឈ្លាសវៃ នោះតម្លៃវាគឺមិនអាចវាស់វែងបានឡើយ ។ នៅគ្រប់ពេលដែលយើងមាន ដោយមិនគិតថ្លៃ ជាចំនួននៃនាទី និងម៉ោងដើម្បីប្រើដូចគ្នា ហើយមិនយូរប៉ុន្មានយើងបានដឹង ដូចដែលទំនុកដំកើងមួយបានបង្រៀនដោយហ្មត់ចត់ថា « ពេលវេលាដើរលឿនណាស់ យើងមិនអាចហៅវាឲ្យត្រឡប់ក្រោយវិញបានឡើយ » ( « Improve the Shining Moments » *Hymns* លេខ 226 ) ។

យើងត្រូវប្រើពេលវេលាដែលយើងមានឲ្យឈ្លាសវៃ ។ ប្រធាន ព្រិកហាំ យ៉ង់ បាននិយាយថា « យើងទាំងអស់គ្នាជំពាក់បំណុលព្រះសម្រាប់សមត្ថភាពក្នុងការប្រើប្រាស់ពេលវេលាដើម្បីទទួលបានប្រយោជន៍ ហើយទ្រង់នឹងឲ្យយើងរៀបរាប់ពីរបៀបដែលយើងប្រើវា » ( *Teachings of Presidents of the Church: Brigham Young* [ ឆ្នាំ 1997 ] ទំព័រ 286 ) ។

ដោយតម្រូវការដែលចង់បានពីយើង នោះយើងត្រូវតែរៀនដាក់អាទិភាពនូវការជ្រើសរើសយើង ដើម្បីឲ្យត្រូវនឹងគោលដៅ ឬហានិភ័យ ដោយបង្អោនទៅតាមការពន្យារពេល និងការចំណាយពេលវេលាយើងយ៉ាងច្រើនទៅលើសកម្មភាពដែលគ្មានប្រយោជន៍ ។ យើងត្រូវបានបង្រៀនយ៉ាងច្បាស់ពីអាទិភាពនានាដោយគ្រូបង្រៀនដ៏ឆ្នើម ពេលទ្រង់បានប្រកាសនៅក្នុងការបង្រៀនរបស់ទ្រង់លើភ្នំថា « ហេតុដូច្នោះហើយ ចូរកុំស្វែងរកអ្វីៗនៃលោកិយនេះឡើយ ប៉ុន្តែចូរអ្នកស្វែងរកដើម្បីកសាងនគរព្រះ ហើយដើម្បីតាំងសេចក្ដីសុចរិតរបស់ទ្រង់ជាមុនសិន »( ដកស្រង់ចេញពីការបកប្រែដោយយ៉ូសែប ស្ម៊ីធ ម៉ាថាយ 6:38 ) ។ ( សូមមើល Dallin H. Oaks « Focus and Priorities » *Liahona* ខែ កក្កដា ឆ្នាំ 2001 ទំព័រ 99--102 *Ensign* ខែ ឧសភា ឆ្នាំ 2001 ទំព័រ 82--84 ) ។

អាលម៉ាបាននិយាយពីអាទិភាព ពេលគាត់បានបង្រៀនថា « ជីវិតនេះក្លាយទៅជាស្ថានភាពពិសោធន៍មួយ គឺជាពេលវេលាសម្រាប់ប្រុងប្រៀបទៅជួបព្រះ » ( អាលម៉ា 12:24 ) ។ របៀបប្រើអំណោយទានដ៏មានតម្លៃល្អបំផុត ដើម្បីរៀបចំខ្លួនជួបព្រះ អាចតម្រូវឲ្យមានការណែនាំមួយចំនួន តែប្រាកដណាស់យើងនឹងដាក់ព្រះអម្ចាស់ និងគ្រួសារយើងនៅខ្ពស់ជាងគេបង្អស់ ។ប្រធាន អុជដូហ្វ បានរំឭកយើងថា « ក្នុងទំនាក់ទំនងគ្រួសារ *ក្ដីស្រឡាញ់* គឺត្រូវការនូវ *ពេលវេលា* » ( « Of Things That Matter Most » *Liahona* និង *Ensign* ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 22 ) ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ពេលជំនួយត្រូវបានស្វែងរកប្រកបដោយការអធិស្ឋាន និងដោយស្មោះត្រង់ ព្រះវរបិតាសួគ៌យើងនឹងជួយយើងឲ្យកំណត់នូវអ្វីដែលគួរតែទទួលបានពេលវេលាយើងលើអ្វីៗផ្សេងទៀត ។

ការប្រើពេលវេលាខ្ជះខ្ជាយគឺទាក់ទងនឹងភាពខ្ជិលច្រអូស ។ ពេលយើងធ្វើតាមបញ្ញាឲ្យឈប់ធ្វើជាមនុស្សខ្ជិលច្រអូស ( សូមមើល គ. និង ស. 88:124 ) នោះយើងត្រូវតែប្រាកដថា ពេលមានភាពមមាញឹក នោះក៏ត្រូវធ្វើអ្វីដែលមានផលប្រយោជន៍ដែរ ។

ឧទាហរណ៍ វាអស្ចារ្យដើម្បីមានមធ្យោយនៃការប្រាស្រ័យទាក់ទងជាទៀងទាត់ដោយគ្រាន់តែប្រើម្រាមដៃយើងនោះ តែចូរយើងប្រាកដថា យើងនឹងមិនញៀននឹងវាឡើយ ។

ខ្ញុំយល់ថា មានមនុស្សមួយចំនួនត្រូវជាប់អន្ទាក់ក្នុងការញៀនដ៏ថ្មីមួយ ---ជាការញៀនដែលទាក់ទាញយើងឲ្យមើល និងផ្ញើសារជាទៀងទាត់ ហើយបានផ្តល់នូវអារម្មណ៍ដ៏ខុសឆ្គងនៃភាពមមាញឹក និងការនាំផលឲ្យ ។

មានអត្ថប្រយោជន៍ជាច្រើននៃការចូលទៅប្រាស្រ័យទាក់ទង និងយកព័ត៌មានបានដោយងាយ ។ ខ្ញុំបានឃើញថាវាមានអត្ថប្រយោជន៍ ដើម្បីចូលទៅរកអត្ថបទ ការនិយាយក្នុងសន្និសីទ កំណត់ត្រាដូនតា ហើយដើម្បីទទួលការរំឭកតាម e-mails, Facebook, tweet និងសារជាដើម ។ ទោះបីជារឿងទាំងនេះល្អក្តី ក៏យើងមិនអាចបណ្តោយឲ្យវាជំនួសនូវអ្វីដែលសំខាន់បំផុតបានឡើយ ។ វានឹងគួរឲ្យសោកស្តាយដល់កម្រិតណាទៅ បើទូរស័ព្ទ និងកុំព្យូទ័រជាមួយនឹងភាពវៃឆ្លាតរបស់វា ជំនួសនូវភាពដ៏ងាយស្រួលនៃការអធិស្ឋានដ៏ស្មោះទៅកាន់ព្រះវរបិតាជាទីស្រឡាញ់គង់នៅស្ថានសួគ៌នោះ ។ ចូរយើងលុតជង្គង់ឲ្យបានលឿនដូចដែលធ្វើការផ្ញើសារផងដែរ ។

ហ្គេមអេឡិចត្រូនិក និងទំនាក់ទំនងតាមអ៊ិនធើរណែតពុំមែនជាការជំនួសជានិច្ចសម្រាប់មិត្តភក្តិពិតដែលអាចផ្តល់ការឱបលើកទឹកចិត្ត ដែលអាចអធិស្ឋានឲ្យយើង ហើយចង់ឲ្យយើងបានល្អបំផុតនោះឡើយ ។ ខ្ញុំមានអំណរគុណអ្វីម្ល៉េះដោយបានឃើញកូរ៉ុម ថ្នាក់ និងសមាជិកក្នុងសមាគមសង្គ្រោះរួបរួមជួយគ្នាទៅវិញទៅមក ។ ក្នុងឱកាសបែបនេះ ខ្ញុំបានឃើញយ៉ាងច្បាស់ពីអ្វីដែលសាវកប៉ុលចង់លើកឡើងថា « អ្នករាល់គ្នាមិនមែនជាអ្នកដទៃ ឬជាអ្នកគ្រាន់តែសំណាក់នៅទៀតទេ គឺជាជាតិតែមួយនឹងពួកបរិសុទ្ធ » ( អេភេសូរ 2:19 ) ។

ខ្ញុំដឹងថា សុភមង្គលដ៏ធំបំផុតរបស់យើងកើតមាន ពេលយើងផ្តោតយកចិត្តទុកដាក់លើព្រះអម្ចាស់ ( សូមមើល អាលម៉ា 37:37 ) និងលើរឿងទាំងឡាយដែលនាំមកនូវរង្វាន់មួយដ៏អស់កល្បជាជាងការផ្តោតយកចិត្តទុកដាក់រាប់ម៉ោងទៅលើការធ្វើបច្ចុប្បន្នភាពក្នុងស្ថានភាពហ្គេមកសិដ្ឋានតាមអ៊ិនធើរណែ-ត និងហ្គេមកំហឹងបក្សីនោះឡើយ ។ ខ្ញុំសូមជម្រុញឲ្យយើងម្នាក់ៗយកកិច្ចការទាំងឡាយដែលបំផ្លាញពេលវេលាដ៏មានតម្លៃរបស់យើង ហើយតាំងចិត្តដើម្បីគ្រប់គ្រងវា ជាជាងបណ្តោយឲ្យវាគ្រប់គ្រងយើង ។

ដើម្បីមានក្តីសុខសាន្តដែលព្រះអង្គសង្គ្រោះបានលើកឡើង ( សូមមើល យ៉ូហាន 14:27 ) យើងត្រូវតែលះបង់ពេលវេលាយើងចំពោះរឿងដែលសំខាន់បំផុត និងរឿងដែលព្រះទ្រង់គិតថាសំខាន់បំផុត ។ ពេលយើងទំនាក់ទំនងនឹងព្រះក្នុងការអធិស្ឋានដ៏ស្មោះត្រង់ អាន និងសិក្សាព្រះគម្ពីររាល់ថ្ងៃ ពិចារណាលើអ្វីដែលយើងបានអាន និងទទួលអារម្មណ៍ រួចហើយអនុវត្ត និងរស់នៅតាមមេរៀនដែលបានរៀន នោះយើងនឹងបានខិតជិតទ្រង់ ។ ការសន្យារបស់ព្រះគឺថា នៅពេលយើងស្វែងរកដោយព្យាយាមចេញពីសៀវភៅដ៏ល្អបំផុត « [ទ្រង់] នឹងប្រទានដំរិះដល់[យើង] ដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ » ( គ. និង ស.121:26 ) ។

សាតាំងនឹងល្បួងយើងឲ្យប្រើពេលវេលាយើងខុស តាមរយៈការអូសទាញដែលក្លែងបន្លំ ។ ទោះជាការល្បួងនឹងកើតឡើងក្តី តែអែលឌើរ ឃ្វីនថិន អិល យុកបានបង្រៀនថា « ពួកបរិសុទ្ធដែលឆ្លើយតបចំពោះសារលិខិតរបស់ព្រះអង្គសង្គ្រោះនឹងមិនត្រូវបានដឹកនាំឲ្យវង្វេងដោយការអូសទាញឲ្យបែកចេញ និងដ៏បំផ្លិចបំផ្លាញឡើយ »(«Are You a Saint? » *Liahona* និង *Ensign* ខែ វិច្ឆិកា ឆ្នាំ 2003 ទំព័រ 96 )។ ហៃរាំ ភេច ជាមនុស្សម្នាក់ក្នុងចំណោមសាក្សីទាំង 8 នៃព្រះគម្ពីរមរមន បានបង្រៀនយើងនូវមេរៀនមួយដ៏មានតម្លៃអំពីការអូសទាញ ។ គាត់មានថ្មមួយដុំ ហើយដោយមើលទៅថ្មនោះ គាត់បានកត់ត្រានូវអ្វីដែលគាត់បានគិតថាជាវិវរណៈសម្រាប់សាសនាចក្រ ( សូមមើល គ. និង ស. 28 ) ។ បន្ទាប់ពីបានកែតម្រូវ មានការពន្យល់មួយបានលើកឡើងថា ថ្មនោះត្រូវបានយកទៅកប់ក្នុងដី ដើម្បីកុំឲ្យមានការរំខានម្តងទៀត ។[1]

ខ្ញុំសូមអញ្ជើញយើងឲ្យកំណត់ការរំខានដែលគ្មានប្រយោជន៍ក្នុងជីវិតយើង ដែលត្រូវការយកទៅកប់នៅក្នុងដី ។យើងត្រូវតែឈ្លាសវៃក្នុងការវិនិច្ឆ័យយើង ដើម្បីឲ្យប្រាកដថា ជញ្ជីងនៃពេលវេលាមានតុល្យភាពត្រឹមត្រូវ ដោយបូកបញ្ចូលទាំងព្រះអម្ចាស់ គ្រួសារ ការងារ និងសកម្មភាពល្អៗផ្សេងទៀត ។ ដូចដែលមនុស្សជាច្រើនបានរកឃើញរួចហើយថា សុភមង្គលក្នុងជីវិតនឹងកើនឡើង កាលណាយើងប្រើពេលវេលាយើងស្វែងរកនូវអ្វីៗដែល « ប្រកបដោយគុណធម៌ គួរស្រឡាញ់ ឬឈ្មោះល្អ ឬក៏គួរឲ្យសរសើរ » នោះ ( មាត្រានៃសេចក្តីជំនឿ 1:13 ) ។

ពេលវេលាដើរលឿនណាស់ ។ ថ្ងៃនេះនឹងក្លាយជាថ្ងៃមួយដ៏ល្អ ដើម្បីមើលឡើងវិញនូវអ្វីដែលយើងកំពុងធ្វើដើម្បីរៀបចំខ្លួនជួបនឹងព្រះ ពីមុនពេលវេលានៃជីវិតរមែងស្លាប់នេះកន្លងផុតទៅ ។ខ្ញុំថ្លែងទីបន្ទាល់ថា មាននូវរង្វាន់ដ៏ធំមួយសម្រាប់អស់អ្នកណាដែលយកពេលវេលាក្នុងជីវិតរមែងស្លាប់នេះ ដើម្បីរៀបចំខ្លួនសម្រាប់ភាពអមតៈ និងជីវិតអស់កល្ប ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. Utah Stake General Minutes, Apr. 6, 1856, LR 9629 11, Vol. 10 (1855--1860), 273 ៖ « ឪពុក [Emer] Harris បាននិយាយថា សាវកបាននិយាយថា យើងត្រូវតែតយុទ្ធនឹងពួកគ្រប់គ្រង និងអំណាចនៃសេចក្ដីងងឹត បងប្រុស Hiram Page  បានជីកយកថ្មីខ្មៅមួយដុំចេញពីដី ហើយដាក់វាចូលក្នុងហោប៉ៅគាត់ ពេលគាត់ទៅដល់ផ្ទះ គាត់បានសម្លឹងមើលថ្មនោះ គាត់បានឃើញប្រយោគមួយលេចឡើង ដូចជាការសរសេរលើក្រដាសដូច្នោះដែរ នៅពេលគាត់សរសេរប្រយោគមួយចប់មិនបានយូរប៉ុន្មានផង ស្រាប់តែប្រយោគមួយទៀតបានលេចឡើង រហូតដល់គាត់សរសេរបាន 16 ទំព័រ ។ បងប្រុសយ៉ូសែបបានប្រាប់ពីការណ៍នោះ មានមនុស្សម្នាក់បានសួរថា យ៉ូសែបតើវាត្រឹមត្រូវដែរទេ គាត់និយាយថាគាត់មិនដឹងទេ តែគាត់បានអធិស្ឋាន ហើយទទួលវិវរណៈថាថ្មនោះគឺបានមកពីអារក្ស ក្រោយមកថ្មនោះត្រូវបានគេបំបែកទៅជាផេះ ហើយការសរសេរទាំងនោះត្រូវបានដុតចោល វាជាកិច្ចការនៃអំណាចនៃសេចក្ដីងងឹត អាម៉ែន » ។